# កម្ពុជា៖ ផែនការយុទ្ធសាស្ត្ររយៈពេលខ្លីរបស់ធនាគារពិភពលោក ឆ្នាំ ២០១៤-២០១៥
# ផែនការពិគ្រោះយោបល់

---

ធនាគារពិភពលោក កំពុងតែធ្វើការពិគ្រោះយោបល់ជាសាធារណៈជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីធ្វើបច្ចុប្បន្នភាពលើការបង្កើតផែនការយុទ្ធសាស្ត្ររយៈពេលខ្លីសម្រាប់ភាពជាដៃគូរវាងប្រទេសកម្ពុជានិងធនាគារពិភពលោកក្នុងឆ្នាំ ២០១៤ និង ២០១៥។

ផែនការយុទ្ធសាស្ត្រនេះ ផ្តល់នូវក្រមខ័ណ្ឌមួយដល់ធនាគារពិភពលោកក្នុងការចូលរួមជាមួយប្រទេសដែលត្រូវអនុវត្តយុទ្ធសាស្ត្រនេះ រហូតដល់យុទ្ធសាស្ត្រ និងក្របខ័ណ្ឌភាពជាដៃគូប្រចាំប្រទេសពេញលេញមួយ ត្រូវបានរៀបចំរួចរាល់។

ធនាគារពិភពលោក កំពុងតែស្នើសុំយោបល់មតិយោបល់ពីរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធនានាអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធ្វើបច្ចុប្បន្នភាពលើការងាររបស់ធនាគារពិភពលោកក្នុងរយៈពេលពីរឆ្នាំខាងមុខ។

កិច្ចពិគ្រោះយោបល់ទាំងនេះ នឹងជួយចង្អុលបង្ហាញអំពីអន្តរាគមន៍ដែលមានប្រសិទ្ធិភាពបំផុតដល់ធនាគារពិភពលោកដើម្បីបន្តកិច្ចការរបស់ខ្លួន និងបង្កើនការគាំទ្រក្នុងការអនុវត្តសកម្មភាពតាមកម្មវិធីរបស់ខ្លួននៅក្នុងប្រទេស។ ធនាគារពិភពលោកស្វែងរកការអនុវត្តល្អពីអន្តរជាតិ ដើម្បីរៀបចំនិងអនុវត្តដំណើរការនៃការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធរបស់ខ្លួន។

### *គោលបំណងនៃកិច្ចពិគ្រោះយោបល់លើផែនការយុទ្ធសាស្ត្រនេះ*

គោលបំណងនៃកិច្ចពិគ្រោះយោបល់លើផែនការយុទ្ធសាស្ត្រនេះ គឺដើម្បីស្នើសុំមតិយោបល់ពីភាគីពាក់ព័ន្ធនានានៅក្នុងប្រទេសដែលផ្តោតការយកចិត្តទុកដាក់និងទំហំការងាររបស់ធនាគារពិភពលោកសម្រាប់ប្រទេសកម្ពុជា នឹងសកម្មភាពនានាដែលធនាគារពិភពលោកលើកស្នើជាមតិយោបល់ដើម្បីអនុវត្តក្នុងភាពជាដៃគូជាមួយប្រទេសកម្ពុជាក្នុងកំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះ និងសំណើសុំយោបល់សម្រាប់ការរៀបចំសកម្មភាពទាំងនេះ។

### *ក្រុមភាគីពាក់ព័ន្ធសំខាន់ៗដែលនឹងត្រូវចូលរួមក្នុងកិច្ចពិគ្រោះយោបល់នេះមានដូចខាងក្រោម៖*

| | |
|---|---|
| រដ្ឋាភិបាល | មន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ជាអ្នកពិភាក្សាសំខាន់របស់រដ្ឋាភិបាល) មន្ត្រីនិងតំណាងក្រសួងពាក់ព័ន្ធព្រមទាំង មន្ត្រីនិងតំណាងស្ថាប័នសាធារណៈ ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ និងគជអប។ |
| រដ្ឋសភា | អ្នកតំណាងសមាជិករដ្ឋសភា |

| | |
|---|---|
| រដ្ឋាភិបាលថ្នាក់ក្រោមជាតិ | តំណាងសមាជិកដែលបានជាប់ឆ្នោត ក្រុមប្រឹក្សាខេត្ត ស្រុក និងឃុំ នៅក្នុងខេត្ត |
| ដៃគូអភិវឌ្ឍន៍ | តំណាងម្ចាស់ជំនួយនិងទីភ្នាក់ងារអង្គការសហប្រជាជាតិ |
| វិស័យឯកជន | តំណាងក្រុមហ៊ុនវិស័យឯកជនក្នុងស្រុក និងអន្តរជាតិ |
| អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល | តំណាងអង្គការមិនមែនរដ្ឋាភិបាលធ្វើការផ្នែកផ្គត់ផ្គង់សេវា និងតស៊ូមតិ ក្រុមផ្តល់យោបល់ ស្ថាប័នស្រាវជ្រាវ គ្រឹះស្ថានអប់រំជាន់ខ្ពស់ តំណាងសហជីពពលកម្ម ។ |
| យុវជន | និស្សិតសាកលវិទ្យាល័យនិងសិស្សវិទ្យាល័យ តំណាងក្រុមយុវជន ។ល។ |

***ដំណើរនៃកិច្ចពិគ្រោះយោបល់***

ដំណើរការនៃកិច្ចពិគ្រោះយោបល់នេះ នឹងរួមបញ្ចូលទាំងការប្រជុំពិគ្រោះយោបល់ទល់មុខគ្នាផងនិងតាមបណ្តាញអ៊ីនធើណេតផងដែរ (ប្រើជាភាសាខ្មែរនិងអង្គគ្លេស) ដើម្បីផ្តល់លទ្ធភាពដល់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមបានកាន់តែច្រើន។ កិច្ចពិគ្រោះយោបល់នឹងគ្រោងចាប់ផ្តើមពីពាក់កណ្តាលខែកុម្ភៈ ឆ្នាំ ២០១៥។ កិច្ចប្រជុំពិគ្រោះយោបល់តាមអ៊ីនធើណេតកំពុងតែដំណើរការ ហើយគ្រោងនឹងបន្តរហូតដល់កិច្ចពិគ្រោះយោបល់ទល់មុខគ្នាត្រូវបានបញ្ចប់។

*កម្មវិធីពិគ្រោះយោបល់តាមអ៊ីនធើណេតៈ*

កម្មវិធីពិគ្រោះយោបល់តាមអ៊ីនធើណេត នឹងមានដាក់បញ្ចូលឯកសារសារតារជាច្រើនដើម្បីជួយឲ្យភាគីពាក់ព័ន្ធទាំងអស់បានចូលរួមក្នុងដំណើរការនៃកិច្ចពិគ្រោះយោបល់នេះប្រកបដោយប្រសិទ្ធិភាពនិងផ្លែផ្កា។ យើងក៏មានតារាងសំណួរនៅលើវេបសាយតផងដែរដើម្បីឲ្យភាគីពាក់ព័ន្ធនានាអាចប្រើដើម្បីផ្តល់នូវមតិយោបល់នានាដោយផ្ទាល់ដោយបំពេញទម្រង់ស្ទាបស្ទង់មតិតាមអ៊ីនធើណេត ឬដោយទាញយកតារាងសំណួរនេះក្នុងទម្រង់ជាវើដ (Word file) ចេញពីវេបសាយត៍ និងផ្ញើត្រឡប់មកវិញតាមហ្វាក់ ផ្ញើជាសំបុត្រ ឬអ៊ីម៉េល មកកាន់ការិយាល័យរបស់ធនាគារពិភពលោកនៅរាជធានីភ្នំពេញ។

កាលបរិច្ឆេទនៃកិច្ចប្រជុំពិគ្រោះយោបល់នេះ ក៏នឹងត្រូវបានដាក់បញ្ចូលផងដែរនៅលើទំព័រវេបសាយពិគ្រោះយោបល់ ដើម្បីឲ្យសាធារណៈជនបានដឹងច្បាស់។

កម្មវិធីពិគ្រោះយោបល់តាមអ៊ីនធើណេតនេះ ក៏នឹងជាវេទិកាមួយដែលភាគីពាក់ព័ន្ធដទៃទៀតអាចទទួលបានព័ត៌មានថ្មីៗអំពីដំណើរការនៃកិច្ចប្រជុំនេះនិងអាចដឹងថា តើមតិយោបល់ដែលខ្លួនបានផ្តល់ក្នុងកិច្ចប្រជុំនេះ (ទាំងមតិយោបល់ផ្តល់តាមអ៊ីនធើណេត ទាំងនៅក្នុងកិច្ចប្រជុំទល់មុខគ្នា) ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្ររយៈពេលខ្លីនេះយ៉ាងដូចម្តេច ហើយប្រសិនបើមិនត្រូវបានដាក់បញ្ចូល មូលហេតុអ្វី។

*កិច្ចប្រជុំទល់មុខគ្នា*

កិច្ចប្រជុំទល់មុខគ្នាសរុបចំនួន ១១កិច្ចប្រជុំ ត្រូវបានគ្រោងរៀបចំធ្វើក្នុងរយៈពេលពីរសប្តាហ៍ជាមួយក្រុមភាគីពាក់ព័ន្ធផ្សេងគ្នា ដូចដែលបានរៀបរាប់ខាងលើ។

កិច្ចប្រជុំនេះគ្រោងនឹងរៀបចំឡើងនៅខេត្ត សៀមរាប កំពង់ចាម ភ្នំពេញ និងខេត្តព្រះសីហនុ។ ភាគីពាក់ព័ន្ធនៅខេត្តជិតខាង នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទាំងនេះដែរ។

| | |
|---|---|
| **សៀមរាប** | អ្នកចូលរួមនឹងត្រូវបានអញ្ជើញមកពីខេត្តសៀមរាប កំពង់ធំ បាត់ដំបង និងបន្ទាយមានជ័យ |
| **កំពង់ចាម** | អ្នកចូលរួមនឹងត្រូវបានអញ្ជើញមកពីខេត្ត កំពង់ចាម ក្រចេះ ស្វាយរៀង និងព្រៃវែង |
| **ភ្នំពេញ** | អ្នកចូលរួមនឹងត្រូវបានអញ្ជើញមកពី ភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ កំពង់ឆ្នាំងនិង ពោធិ៍សាត់ |
| **ព្រះសីហនុ** | អ្នកចូលរួមនឹងត្រូវបានអញ្ជើញមកពីខេត្ត ព្រះសីហនុ កំពត កោះកុង និងតាកែវ |

ខេត្តទាំងនេះ ត្រូវបានជ្រើសរើសជាទីតាំងកណ្តាលសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់សម្រាប់ហេតុផលភស្តុភារផង (ខេត្តទាំងនេះផ្តល់លក្ខណៈងាយស្រួលដល់អ្នកចូលរួមក្នុងការធ្វើដំណើរមកប្រជុំ) និងដោយសារក្នុងខេត្តទាំងនេះមានអនុវត្តគម្រោងដែលគាំទ្រហិរញ្ញវត្ថុដោយធនាគារពិភពលោកច្រើនជាងគេបំផុតនៅថ្នាក់ខេត្ត ស្រុក និងឃុំ។

ធនាគារពិភពលោក នឹងរ៉ាប់រងការចំណាយលើការធ្វើដំណើររបស់អ្នកចូលរួមដែលត្រូវបានអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់នេះ។

បណ្តាញអង្គការក្រៅរដ្ឋាភិបាលសំខាន់ចំនួនពីរគឺ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) និងវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ត្រូវបានស្នើរសុំឲ្យជួយជ្រើសរើសតំណាងអង្គការសង្គមស៊ីវិលដើម្បីចូលរួមក្នុងកិច្ចពិគ្រោះយោបល់ទល់មុខគ្នា។ ចំណែកឯ សមាគមយុវជនខ្មែរ (KYA) ក៏ត្រូវបានស្នើរសុំឲ្យជួយជ្រើសរើសតំណាងយុជនឲ្យចូលរួមផងដែរ។

***ទម្រង់៖*** កិច្ចប្រជុំពិគ្រោះយោបល់ទល់មុខគ្នានេះ ភាគច្រើននឹងត្រូវបានរៀបចំក្នុងលក្ខណៈជាការពិភាក្សាតាមក្រុមគោលដៅ ដើម្បីឲ្យក្រុមនីមួយៗ អាចរកមើលបញ្ហានានាឲ្យបានស៊ីជំរៅ។ ការពិភាក្សានេះ នឹងត្រូវរៀបចំឡើងតាមលំដាប់នៃសំណួរណែនាំ (តម្រូវទៅតាមក្រុមភាគីពាក់ព័ន្ធនីមួយៗ)។ កិច្ចប្រជុំទាំងនេះ រំពឹងថានឹងមានរយៈពេលបីម៉ោង បូករួមទាំងការពិភាក្សាតាមក្រុម និងការរាយការណ៍ត្រលប់អំពីលទ្ធផលនៃការពិភាក្សានោះ ។

*ភាសា* ៖ កិច្ចពិគ្រោះយោបល់នេះនឹងនិយាយជាភាសាអង់គ្លេស ដោយមានបកប្រែជាភាសាខ្មែរ សម្រាប់ក្រុមភាគីពាក់ព័ន្ធដូចជា រដ្ឋាភិបាល រដ្ឋសភា វិស័យឯកជន និងដៃគូអភិវឌ្ឍន៍។ សម្រាប់ក្រុមភាគីពាក់ព័ន្ធដូចជា រដ្ឋាភិបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល និងយុវជន កិច្ចពិភាក្សានេះនឹងប្រើភាសាខ្មែរដោយមានបកប្រែប្រដេញជាភាសាអង់គ្លេស។ កម្មវិធីពិគ្រោះយោបល់តាមអ៊ីនធើណេត នឹងប្រើភាសាខ្មែរផងនិងភាសាអង់គ្លេសផង។

***មតិត្រឡប់របស់ភាគីពាក់ព័ន្ធ***៖ កំណត់ត្រាសង្ខេបកិច្ចពិគ្រោះយោបល់នេះនឹងត្រូវផ្ញើជូនតាមអ៊ីម៉េលទៅកាន់អ្នកចូលរួមទាំងអស់ដើម្បីពិនិត្យមើលឡើងវិញនិងអនុម័តក្នុងរយៈពេលមួយសប្តាហ៍។ រាល់ការកែតម្រូវទាំងអស់នឹងត្រូវបានដាក់បញ្ចូលតាមលទ្ធភាពដែលអាចធ្វើទៅបាន ហើយសេចក្តីសង្ខេបនឹងត្រូវធ្វើបញ្ចប់។ សេចក្តីសង្ខេបអង្គប្រជុំបញ្ចប់ រួមទាំងបញ្ជីរាយនាមអ្នកចូលរួម នឹងត្រូវបានចុះផ្សាយនៅលើទំព័រវេបសាយត៍កិច្ចពិគ្រោះយោបល់នេះ លើកលែងតែកិច្ចប្រជុំជាមួយក្រុមតំណាងឲ្យរដ្ឋាភិបាល។ សេចក្តីសង្ខេបនៃកិច្ចប្រជុំទាំងអស់នឹងរៀបចំជាភាសាអង់គ្លេស។ សម្រាប់កិច្ចប្រជុំពិភាក្សាដែលរៀបចំដោយប្រើភាសាខ្មែរ និងមានសេចក្តីសង្ខេបអំពីលទ្ធផលនោះជាភាសាខ្មែរ។

សេចក្តីសង្ខេបចុងក្រោយដែលមានគូសចំណាំលើមតិយោបល់នានាដែលទទួលបានពីកិច្ចប្រជុំទាំងអស់ និងសំណួរនៅលើអ៊ីនធើណេត នឹងត្រូវយកទៅធ្វើបទបង្ហាញជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងកិច្ចប្រជុំបូកសរុបក្រោយកិច្ចពិគ្រោះយោបល់ត្រូវបានបញ្ចប់។ សេចក្តីសង្ខេបនេះ ក៏នឹងត្រូវបានចុះផ្សាយនៅលើទំព័រវេបសាយត៍ពិគ្រោះយោបល់ នៅជិតចុងបញ្ចប់នៃដំណើរការពង្រាងផែនការយុទ្ធសាស្ត្ររយៈពេលខ្លី ISN ។ សេចក្តីសង្ខេបនោះក៏មានឯកសារពន្យល់អំពីហេតុផលដែលមតិត្រឡប់នោះមិនត្រូវបានដាក់បញ្ចូល ហើយនឹងដាក់បញ្ចូលជាកញ្ចប់ឯកសារភ្ជាប់ជាមួយផែនការយុទ្ធសាស្ត្ររយៈពេលខ្លី ISN ចុងក្រោយ ដែលយកទៅបង្ហាញដល់ក្រុមប្រឹក្សាភិបាល។